ឧបសោសង្ហា

# បច្ច័យភាព នៃ បរាជ័យ របប ផ្តាច់ការ



ដំបៅ នៃ កម្ពុជា

## មាតិការឿង


**មូលហេតុ**..................................................................................2

**ប្រតកម្ម អហិង្សា**..................................................................4

**ប្រតកម្ម ហិង្សា**......................................................................6

**មធ្យោបាយ**..............................................................................7

# បច្ច័យភាព[1] នៃ បរាជ័យរបបផ្តាច់ការ

## មូលហេតុ

### ច្បាប់ធម្មជាតិ

គេ តែងតែនិយាយថា អំណាចផ្តាច់ការ ត្រូវ តែ រលំ នៅពេលណាមួយ ជាពុំខាន។ ឧទាហរណ៍ មានច្រើនណាស់ ហើយ គេមិនបាច់ ទៅរកវា ពីបុរាណកាល និងសម័យយុគកណ្តាល មក បង្ហាញ នូវ បរាជ័យ ពួក ជនផ្តាច់ការ ដែល ជា មនុស្ស ឃោឃៅ មានឈាម ប្រឡាក់ដៃ ច្រើន ឬ តិចតួចក្តី ដែលត្រូវបាន ក្រុម ឬ ជន ដែល នៅក្បែរ ខ្លួន ឬ ត្រូវ ក្រុមមនុស្ស ក្រេវក្រោធ សម្លាប់ ចោល ជួនកាល យ៉ាងសាហាវ បំផុត។ លោក ប្រធានាធិបតីសហរដ្ឋ អាមេរិក អូប៉ាម៉ា បានថ្លែង ថា ជនផ្តាច់ការ ទាំងនោះ មិនសូវ ទទួលមរណភាព នៅលើគ្រែ របស់ខ្លួន ដោយសុខសាន្ត នោះឡើយ។

ការពិនិត្យកត់ត្រា នេះ អាច ចាត់ទុក បានជា សេចក្តី លើក ទឹកចិត្ត ដល់ អ្នកតស៊ូប្រឆាំងនឹង របបផ្តាច់ការ នៅក្នុង ពិភពលោក។ ជួនកាល ជនផ្តាច់ការ ខ្លះ ត្រូវបាន ប្រជាពលរដ្ឋ ទម្លាក់ចោល យ៉ាង ងាយស្រួល បំផុត គ្រាន់តែ នាំគ្នាស្រែកប្រឆាំង តែប៉ុណ្ណោះ ព្រោះ របបផ្តាច់ការ វា ទុំ ហើយ ស្អុយរលួយ ជ្រុះ ខ្លួនឯង ស្របតាម ច្បាប់ នៃ ធម្មជាតិ ដូច ករណី លោក Nicolae Ceausescu អតីត ប្រធានាធិបតី ប្រទេស Roumanie។ ករណី នេះ មិនមែន ជា ករណី ឯកា នោះដែរ នៅក្នុង ប្រវត្តិសាស្ត្រ នៃ មនុស្សជាតិ។ អ្វី ជា អកុសល ត្រូវ តែរលាយព្រោះ លោកា (univers) គ្រប់គ្រង ដោយ ច្បាប់ធម្មជាតិ ដែល មាន សុខដុម ជា វិធី នៃ ដំណើរការ នៃ ធម្មជាតិ ហើយ បង្ក្រាប ជា និច្ច នូវ អ្វីដែល គ្មាន សណ្តាប់ធ្នាប់ គឺ អកុសល នោះ ឯង។ បដិវត្តន៍ អហិង្សា ដូចយ៉ាង បាតុកម្ម ប្រជាជន ប្រឆាំងនឹង អំណាចផ្តាច់ការ ក៏ ជា អភិក្រម ជា ធម្មជាតិ នូវ ការគ្រោបសង្កត់ កម្លាំង កុសល ទៅលើ កម្លាំង អកុសល ដើម្បី ស្វែងរកសុខដុម ក្នុងសង្គមជាតិ នោះ ឯង។ ដូច្នេះ ពាក្យ បដិវត្តន៍ មិនសុទ្ធ តែ មាន ន័យ ថាជា អំពើ ហិង្សា នាំ បង្ហូរ ឈាម នោះឡើយ ព្រោះ បដិវត្តន៍ មាន ប្រភព ចេញ ពី សេរីភាព ហើយ សេរីភាព ជា តម្លៃ សជ្ឈន្តិកៈ (តម្លៃ មាន នៅក្នុង ធាតុ មនុស្សលោក) ដែល ជា តម្លៃ ធម្មជាតិ។ មនុស្សលោក ពុំ អាច អត់ទ្រាំ បាន ជា ថេរចិរកាល នៅចំពោះ ការជិះជាន់ ពីមនុស្សដទៃ បាន នោះឡើយ។ ការអត់ទ្រាំ វាមាន កំរិត អាចអត់ឱនបាន (seuil de tolérance) របស់វា នៅពេលណា អំពើ ហិង្សា វា ក្លាយ ជា

[1] បច្ច័យភាព= ទំនង ; logique។

ទណ្ឌកម្ម មិនអាចទ្រាំបាន ពេលនោះ វា ច្បាស់ជា ជុំរុញ មនុស្សលោក ឲ មាន ប្រតិកម្ម តាម លទ្ធភាព ខ្លួន ជា មនុស្សលោក ដែល ជា ធាតុ នៃសេរីភាព ប្រើ ប្រឆាំងនឹងអំពើ ហិង្សា នោះ ជា ពុំខាន។ ទង្វើ នេះ ជា ច្បាប់ ធម្មជាតិ ដែល ត្រូវមានកើតឡើងជានិច្ច។

## អន្ធការនិយម[2]

នៅក្នុង របប ផ្តាច់ការ តែងតែ ផលិត គ្រប់ អំពើ អកុសល ដែល នាំ ឲ វា ក្លាយ ទៅ ជា ធាតុ នៃ របប ហើយ នាំ បង្កើត ឲមាន សង្គមមួយ នៅក្នុងនោះ មាន មនុស្ស អាត្មានិយម ជាច្រើន គិត តែរស់ សំរាប់ តែ ការពារ ប្រយោជន៍ បុគ្គល ឬ ក្រុមគ្រួសារ របស់ខ្លួន។ អត្ថភាព នៃ របប ជីវភាព បែបនេះ វា នាំ បន្ថប់ នូវ សីលធម៌ ដល់ សង្គម ហើយ វា ក្លាយ ជា ជម្រក ដ៍កក់ក្តៅ របស់ អំណាចផ្តាច់ការ ព្រោះ ពួក អ្នកផ្តាច់ការ និយម និង ពួក ជនអាត្មានិយម មាន ធាតុ ជា លុទ្ធបុគ្គល (បុគ្គលលោភ) ដូចគ្នា ជា មនុស្ស ឥតស្គាល់ នូវ សភាវៈ (កុសល និង អកុសល) ហើយ មាន ប្រយោជន៍ រួម គឺ ប្រយោជន៍ ឯកជន ដែលវា ជា ការវិនាស ដល់ ប្រយោជន៍ជាតិ និង ប្រយោជន៍សាធារណៈ។ រាគៈ (តណ្ហា) មានៈ (អំនួត) ជា មូលដ្ឋាន សំរាប់ រស់នៅ ដើម្បី បង្ហាញ នូវ ភោគទ្រព្យ ដើម្បី ធ្វើ ការប្រជែង ចង់ ឈ្នះចាញ់គ្នា។ អន្ធការនិយម កើត មក ពី អវិជ្ជា ដែល វា ផ្ទុយ ពី មាន វិជ្ជា ព្រោះ មាន វិជ្ជា គឺ មាន ការត្រិះរិះត្រូវ និយាយត្រូវ និង ធ្វើការងារត្រូវ។ មនុស្សលោក ទោះបី មាន ចំណេះ ខាង មុខវិជ្ជា អ្វីមួយ ក៏អាចជា មនុស្ស អវិជ្ជា បាននោះដែរ បើខ្លួន យក ចំណេះ ចេះដឹងនោះ សំរាប់ តែ បំរើ រាគៈនិង មានៈ របស់ខ្លួន។ នៅក្នុង របប ផ្តាច់ការ មាន អ្នកចេះដឹងខ្លះ យក ចំណេះខ្លួនទៅលក់ដូរ ដើម្បី រក ផលប្រយោជន៍ ផ្ទាល់ខ្លួន ទោះបីប្រយោជន៍នោះ នាំឲអ្នកឯទៀតរងទុក្ខវេទនា យ៉ាងណា ក៏ដោយ។ អ្នកចេះដឹង ទាំងនោះ មិន ជួយ ជា ប្រទីប ទ្រោលបំភ្លឺ សង្គម មនុស្សលោក ឲ មាន ពន្លឺបញ្ញា នោះឡើយ ដែល នាំ បង្កើត សង្គម គ្មាន សីលធម៌។ តែ អ្នកអវិជ្ជា ភ្លេចគិតថា សង្គម គ្មាន សីលធម៌ គឺជា សត្រូវនឹង របប ផ្តាច់ការ ព្រោះ នៅក្នុង សង្គម នោះ មាន មនុស្ស អវិជ្ជា ជាច្រើន ហើយ នៅពេលមួយ មនុស្សអវិជ្ជា ទាំងនោះឯង នាំគ្នាកាប់ សម្លាប់ គ្នា ដើម្បី ការពារ ឬ ស្វែងរក ផលប្រយោជន៍ រៀងៗខ្លួន ដែល ជា កត្តាដែល នាំ ឲ របប ផ្តាច់ការ កំទិចខ្លួន ដោយខ្លួនឯង ព្រោះ មនុស្សខ្លាំង អវិជ្ជា តែងតែ មាន មនុស្សខ្លាំង អវិជ្ជា ម្នាក់ទៀត មក ធ្វើ ឲ ខ្លួន អន្តរធាន ជានិច្ច ដ្បិទ អកុសល វា រស់នៅ ក្នុង បច្ច័យភាព (logique) នៃ អំពើ ហិង្សា គឺ ថា ការកាប់សម្លាប់គ្នា ដើម្បី រស់។ បច្ច័យភាព នេះឯង ដែល ជា បច្ច័យភាព នៃបរាជ័យរបស់របប ផ្តាច់ការ។

---

[2] លទ្ធិទុកឲប្រជាការល្ងង់ ; obscurantisme។





## ដំណើរ នៃ មនុស្សជាតិ

ដំណើរ នៃ មនុស្សជាតិ គឺ ដើរ ទៅរក ការរីកចំរើន ដាច់ខាត នៃ សីលធម៌ សំរាប់ មនុស្សលោក ដូច្នេះ អំណាច ផ្តាច់ការ ជា បដិចរន្ត (contrecourant) ដែល ពុំ អាច ទប់ទល់ ជា ថេរចិរកាល នឹង ដំណើរ នៃ មនុស្សជាតិ បាន នោះឡើយ ព្រោះ មនុស្សជាតិ ជា មជ្ឈដ្ឋាន នៃ អារ្យធម៌ ដែល ជា ចលករ នៃ ការរីកចំរើន ដ្បិទ មនុស្សលោក ជា នាដការ នៃ ធម្មជាតិ ដែល មាន វិចារណញ្ញាណ ជា សម្បទាពីកំណើត(doué)។ មនុស្សលោក នេះឯង ធ្វើសមោធនា (បញ្ចេញ) នូវ បញ្ញា ព្រោះ ខ្លួន ជា សត្វលោក ចេះ ពិចារណា ដែល នាំ ឲ ខ្លួន មាន សភារៈ។ មនុស្សលោក ជា ៖ អំណាច, កម្លាំង, សេចក្តីសុខ, សេចក្តីចំរើន, កូនចៅ, រដូវ និង មិត្តសម្លាញ់។ កត្តា ទាំង ៧ យ៉ាងនេះ ជាមូលដ្ឋាន នៃកុសល របស់ មនុស្សលោក ដែល នាំ ឲ មនុស្សលោក មាន ភវន្ទបនិស្ស័យ (paix intérieur) ដែល ជា ធាតុដើម របស់ មនុស្សលោក។ តែ នៅ ក្នុង ធាតុដើម នៃ មនុស្សលោក ក៏មានធាតុឃោឃៅ ជាវិភូ (barbarie en puissance) មួយ ចំណែក ដែរ ដែល នាំ ឲ មនុស្ស មួយ ជំពូក ប្រព្រឹត្តិ អំពើ អមនុស្សធម៌។ មនុស្សលោក ជំពូកនោះ គេទុកជា អមនុស្ស ឬ ជា តិរច្ឆាន។ តែ អមនុស្ស ទាំងនោះ កាន់តែ មាន ចំនួន ថយទៅៗ នៅ ក្នុង មនុស្សជាតិ ព្រោះធាតុ ឃោឃៅ នោះ ជា អនារ្យធម៌ ពុំអាចរស់នៅបាន យូរ នៅ ក្នុង មនុស្សជាតិ ដែល ជា អារ្យធម៌ នោះឡើយ។

---

## ប្រតកម្ម អហិង្សា

---

មូលហេតុ ចំបង បី យ៉ាង ដែល យើង លើក មកបង្ហាញ ខាងលើនេះ ជា អំពី បរាជ័យ នៃ របប ផ្តាច់ការ ជា វិវត្តន៍ ជា ធម្មជាតិ នៃ មនុស្សជាតិ។ មនុស្សលោក រស់ នៅក្នុង ការវិវត្តន៍ នេះ នាំឲខ្លួន ធ្វើសមាច័យ (ប្រមូលផ្តុំ) នៃ ចំណេះ គ្រប់បែបយ៉ាង ដើម្បីសេចក្តីចម្រើន នៃ មនុស្សជាតិ។ ពី ទំនាន់ (génération) មួយ ទៅទំនាន់មួយ មនុស្សលោក នាំគ្នា បង្កើត និង ធ្វើបុនក្ការ (rénover) អារ្យធម៌ ដែល មានតម្លៃ ពីរ យ៉ាង សំរាប់ខ្លួន៖ តម្លៃ សីលធម៌ និង តម្លៃ សម្ភារៈ។ តម្លៃ សីលធម៌ គឺ ជា គ្រឹះនៃ សេចក្តីថ្លៃថ្នូរ (dignité) របស់ មនុស្សលោក រីឯ តម្លៃ សម្ភារៈ គឺ សំរាប់ សម្រួល នូវ ការរស់ នៅ ក្នុងផ្នែក សម្ភារៈ នៃ មនុស្សលោក ដែល លោក Karl Marx បែងចែក ទី១ ជា **ឧបរិរចនាសម្ពន្ធ**[3] និង ទី២ ជា **ហេដ្ឋារចនាសម្ព័ន្ធ**[4]។ ការបែងចែក នេះឯង ដែល នាំឲមាន

---

[3] Superstructure.
[4] Infrastructure.

ការបែងចែក ពាក្យ វប្បធម៌ សំរាប់ សំដៅ លើ ជីវិតផ្នែកស្មារតី និង ពាក្យ អារ្យធម៌ សំរាប់ សំដៅ លើ ជីវិតផ្នែកសម្ភារៈ នៃ មនុស្សលោក។

ការស្គាល់ នៃ តម្លៃ សេចក្តីថ្លៃថ្នូរ នៃ មនុស្សលោក ដែល នាំ មនុស្សលោក មាន ប្រតិកម្ម ប្រឆាំងនឹង អំពើ អ្វីមួយ ដែលប៉ះពាល់ ដល់ សេចក្តីថ្លៃថ្នូរ នេះ។ ប្រតិកម្ម ជាបឋម គឺ មនុស្សលោក នាំគ្នាៈ

- ជឿលើ អាទិទេព ធម្មជាតិ ដែលខ្លួន ទុកជា អ្នកបង្កើត លោកា និងការពារ សេចក្តីសុខ នៃ មនុស្សលោក តាម ការបួងសួង ដើម្បី អាច រស់នៅក្នុង សេក្តីថ្លៃថ្នូរ ជា មនុស្សលោក។

- បង្កើត សាសនា ទុក ជា ទិដ្ឋិ (dogme) នៃ រូបមន្តប្រតិបត្តិ[5] ដើម្បី រស់នៅ ក្នុង សេចក្តីថ្លៃថ្នូរ នៃ មនុស្សលោក។

- បង្កើត ច្បាប់ សំរាប់ ការពារ សិទ្ធិ សេរីភាព ដែល ជា តម្លៃ នៃ សេចក្តី ថ្លៃថ្នូរ របស់ មនុស្សលោក។ ច្បាប់នេះឯង ដែល នាំឲ មនុស្ស ម្នាក់ៗ មាន សិទ្ធិ ការពារ ខ្លួន នៅចំពោះមុខ ការបំពាន ពី ជនដទៃ មក លើ រូបខ្លួន។ ការការពារ សិទ្ធិ នេះ ជួនកាល វាអាច ជា ប្រតិកម្ម ហិង្សា ជួនកាល វា អាច ជា អហិង្សា តែ យ៉ាងណាក្តី វា មាន ច្បាប់ ជា អ្នកគ្រប់គ្រងវា ជានិច្ច។

យើងឃើញថា គោលបំណង សំខាន់ របស់ មនុស្សលោក គឺ ការរស់នៅ នៅក្នុង សេចក្តីថ្លៃថ្នូរ ដែលជាធាតុដើម របស់ មនុស្សលោក ដែល ព្រះអង្គ Dalaï-Lama ទុកជា សីលធម៌ គ្រហស្ថ (éthique séculière)[6] ឬ សីលធម៌ មនុស្សធម៌ ដែល ជា សីលធម៌ មាន សារៈសំខាន់ ជាងសាសនា ទៅទៀត ព្រោះ មនុស្សលោក គ្មាន សាសនា ពីកំណើត នោះទេ តែ មាន សីលធម៌ ជា ធម្មជាតិ របស់ខ្លួន។ ទស្សនៈ នេះ ដូច គ្នា នឹង ទស្សនៈ របស់ លោក Albert Schweitzer តែ ប្រើ រូបមន្ត ផ្សេង គឺ ថា «ការគោរព នៃ គ្រប់ របៀប រស់នៅ របស់ជីវិត សត្វលោក»។
សីលធម៌ មនុស្សធម៌ មិន ស្ថិត នៅ លើ តែ តម្លៃ ក្រៅ ឬ សម្ភារៈ តែ ក៏ជាតម្លៃក្នុងដូចយ៉ាងៈ ករុណា, ការរក្សា ស្មារតី នៃ គំនិត និង ***ជវនចិត្តទៅរកសុភមង្គល***[7]។ ព្រះអង្គ Dalaï-Lama មានព្រះបន្ទូលថា «បើ យើង ចង់ មាន សេចក្តីសុខសប្បាយ យើង ត្រូវ មានករុណា ហើយ យើង ត្រូវ មានបំណង ឲ អ្នកដទៃ មាន សេចក្តីសុខ នោះដែរ នៅ

---

[5] Formule exécutoire។
[6] L'appel au monde du Dalaï-Lama។ សីលធម៌ ដែល មិនមែន ឈរលើ ទិដ្ឋិ នៃ សាសនា។
[7] Aspiration au bonheur។

# ប្រតកម្ម ហិង្សា

នៅ ចំពោះ មុខ អំពើ ហិង្សា អមនុស្សធម៌ តើ មនុស្សលោក ត្រូវ តែ រក្សាស្មារតី គំនិត នៃ សីលធម៌ គ្រហស្ថ ហើយ រង់ចាំ អំពើ ហិង្សា នោះ វា រលត់ ទៅវិញ ដោយខ្លួនឯង បានដែរ ឬទេ ? តាម ទស្សនៈ របស់ លោក Gandhi និង ព្រះអង្គ Dalaï-Lama គេ អាច ទុក ជា ចម្លើយ ដែលធ្វើ ឲ គ្មាន មាន មន្ទិល នោះឡើយ គឺថា មិនត្រូវ ប្រើ អំពើ ហិង្សា ទៅ ប្រឆាំងនឹង អំពើ ហិង្សា ព្រោះ វា រិតតែបន្ថែម ឲមាន អំពើ ហិង្សា បន្ត មិនចេះចប់។ តែ ចម្លើយ បែបនេះ វា គ្មាន ជាឯកច្ឆន្ទ សំរាប់ ធ្វើ ជាលំអាន ប្រកប ដោយ ប្រសិទ្ធិភាព នោះទេ ព្រោះ នៅ ក្នុងលោកនេះ នៅ មាន មនុស្សពាល ជា តិរច្ឆាន ដែល ទុក អំពើ ហិង្សា ជា ឧបករណ៍ សំរាប់ ការពារ ផលប្រយោជន៍ ឬ ទុក ការកាប់ សម្លាប់ មនុស្ស ជា ការកំសាន្ត របស់ ខ្លួន។ ការដែលនាំ ឲមាន គ្រោះថ្នាក់ បំផុត គឺថា អ្នកមានវិជ្ជា មាន បំណង ចង់ អប់រំ មនុស្ស តិរច្ឆាន ឲចេះដឹង អំពី សីលធម៌ ឬ អ្នកប្រាជ្ញ ចង់ ធ្វើ ជា ទីព្រឹក្សា ជនផ្តាច់ការ ដើម្បី បន្ថយ ឥទ្ធិពល ក្រុម មនុស្សខូច នៅជុំវិញ ជនផ្តាច់ការ នោះ ព្រោះ មនុស្ស តិរច្ឆាន ឬ ជនផ្តាច់ការ និង ក្រុមបក្សខ្លួន ស្គាល់តែ អកុសល ដូច្នេះ បើ យោបល់ ស្តីពី យុត្តិធម៌ និង ករុណា របស់ អ្នក មានវិជ្ជា និង អ្នកប្រាជ្ញ ដែល វា គ្មានមាន នៅក្នុងបញ្ជីលំដាប់ (répertoire) នៃ អកុសល ហើយគ្មាន ប្រយោជន៍ ដល់ពួកនោះ វា រិតតែ នាំ លើកកម្លាំងចិត្ត វា ដើម្បី ប្រព្រឹត្ត អំពើអកុសល កាត់តែខ្លាំងទៅទៀត ព្រោះ យុត្តិធម៌ ក្តី ករុណា ក្តី វា គ្មាន ហុច ប្រយោជន៍ អ្វី ដល់ខ្លួន នោះឡើយ។

ហេតុនេះឯង បានជា នៅ ក្នុង ប្រទេស មាន នីតិរដ្ឋ មាន ច្បាប់ សំរាប់ បង្ក្រាប ជួនកាល ត្រូវ ប្រើ អំពើ ហិង្សា តែ អំពើ ហិង្សា នោះគឺ ស្ថិត នៅ ក្រោម ការ គ្រប់គ្រង នៃ ច្បាប់ ខុស ពី ជនពាល ប្រើ អំពើ ហិង្សា តាម ទំនើងចិត្ត របស់ ខ្លួន។ អំពើ ហិង្សា នៅក្រោម ការគ្រប់គ្រោង នៃ ច្បាប់ គឺ ជា ច្បាប់ សំរាប់ រក្សា សេចក្តីថ្លៃថ្នូរ នៃ មនុស្សលោក ដែល មាន សីលធម៌ គ្រហស្ថ ជា ធាតុ ពីកំណើត របស់ ខ្លួន។ តែ មនុស្ស ទោះបី កើត ចេញ ពី ប្រភព តែមួយ នៃ មនុស្សជាតិតែងតែ ទទួល ឥទ្ធិពល ពី ទីកន្លែង (milieu) និង ខណៈ (moment) ដែលខ្លួន កំពុង រស់នៅ ដែល លោក



# បច្ច័យភាព នៃ បរាជ័យ របប ផ្តាច់ការ

សេរីការ

Hyppolyte Taine[8] បែងចែក ការវិវត្តន៍ នៃ មនុស្សលោក ក្រោម ឥទ្ធិពល បី យ៉ាង ៖ អំបូរ, ទីកន្លែង និង ខណៈ។ ដូច្នេះមនុស្ស រស់នៅ ក្នុង សង្គម មានអារ្យធម៌ ខ្ពង់ខ្ពស់ ឬ ក្នុង មជ្ឈដ្ឋាន គ្រួសារ មានករុណា អាច នឹង ជួយ សីលធម៌គ្រហស្ថ ដែល ជា ធាតុ កំណើត របស់ ខ្លួន ឲ វិកចំរើន បាន រហ័ស ជាងមនុស្ស ដែល មានកំណើត នៅក្នុង សង្គម ដែល មាន អារ្យធម៌ ទន់ខ្សោយ ឬ ក្នុងមជ្ឈដ្ឋាន គ្រួសារ មាន ករុណា កំរិតទាប។ ការពិនិត្យកត់ត្រា នៃ ភាព ខុស គ្នា នេះ ឯង ដែលនាំឲ មនុស្សលោក នាំ គ្នា បង្កើត ច្បាប់ សំរាប់គ្រប់គ្រង សង្គមជាតិ និមួយៗ បង្កើត លទ្ធិប្រជាធិបតេយ្យ សំរាប់ គ្រប់គ្រង កិច្ចការ នយោបាយ ដែល ទុក សេចក្តីថ្លៃថ្នូរ នៃ មនុស្សលោក ជា ខ្លឹមសារ នៃ ច្បាប់ និង លទ្ធិប្រជាធិបតេយ្យ ជា ក្បួនដឹកនាំជាតិ។

## មធ្យោបាយ

ទស្សនៈ ទុកឲ អំពើ ហិង្សា ប្រព្រឹត្តិ ដោយ ជនតិរច្ឆាន ឬ របបផ្តាច់ការ រលត់ ខ្លួន ឯង គឺ គ្រាន់ តែ ជា ទស្សនៈ ឈរ លើ កង្វះ មធ្យោបាយ សំរាប់ បង្ក្រាប តែ ប៉ុណ្ណោះ ដូច្នេះ វា ពុំ អាច យកមកធ្វើ ជាលំអានសាកល បាននោះឡើយ។ ព្រះអង្គ Dalaï-Lama ប្រើ យុទ្ធសាស្ត្រ អហិង្សា ប្រឆាំងនឹង នយោបាយ រទសានុពន្ធន៍ (annexion) ប្រទេស ទីបេ ពី សំណាក់ ប្រទេសចិន គឺ ជា ទង្វើ កង្វះ មធ្យោបាយ សំរាប់ ការពារ អធិបតេយ្យភាព និង បូរណភាពទឹកដី ប្រទេស ទីបេ នោះឯង។ ព្រះអង្គ នៅ មាន សង្ឃឹម ជានិច្ច នឹងឃើញ ប្រទេស ព្រះអង្គ ទទួលបាន ឯករាជ្យ នៅ ពេល ព្រះអង្គ កំពុងមានជីវិត។ ខន្តី និង សុទិដ្ឋិនិយម នេះ នាំឲ ព្រះអង្គ បាន ទទួល រង្វាន់ ណូបែល សន្តិភាព តែ សួរថា តើ ជា តម្លៃការខាតបង់ ច្រើនប៉ុណ្ណា ដល់ ប្រជាពលរដ្ឋ ទីបេ ? ដូចគេឃើញស្រាប់ហើយ ថា មាន ប្រជាជន ចិន រាប់លាន នាក់ ចូល មក រស់នៅ ក្នុង ប្រទេស ទីបេ ដែល នាំឲ ទីបេ បាត់បង់ វប្បធម៌ជាតិ ដែល ជា ព្រលឹង នៃ ប្រជាជាតិ និមួយៗ។ យុទ្ធសាស្ត្រ អហិង្សា របស់ ព្រះអង្គ Dalaï-Lama នៅក្នុង បរិបទ ប្រទេស ទីបេ ខ្វះមធ្យោបាយ ការពារជាតិ នៅ ចំពោះ មុខ មហាអំណាច ចិន វា ពិតជា វិធីសាស្ត្រមួយ ត្រឹមត្រូវដែរ ព្រោះ បើនឹង ប្រើអំពើ ហិង្សា មានមធ្យោបាយ ជាន់ទាប តបនឹង អំពើ ហិង្សា របស់ មហាអំណាច ចិន កុម្មុយនិស្ត វាមានលទ្ធផល អវិជ្ជមាន គឺ នាំឲ ប្រជាពលរដ្ឋ ទីបេ ស្លាប់ ឥតប្រយោជន៍ ព្រោះ វាជា ការប្រយុទ្ធ វិសមៈ រវាង អ្នក

[8] Histoire de la littérature Anglaise.

ខ្សោយ ទល់ នឹង អ្នកខ្លាំង តែ វិធីសាស្ត្រ នេះ មិន បាន យក កត្តា មានៈតស៊ូតត ខ្លាច ហត់នឿយ ដែល ជា កម្លាំង ចិត្ត អាច យក ឈ្នះ នឹង មធ្យោបាយ សម្ភារៈ សម្បើម បាន ដូច មាន ឧទាហរណ៍ ជា ច្រើន សំរាប់ យកមក ពិភាក្សាទល់នឹង យុទ្ធសាស្ត្រ របស់ ព្រះអង្គ Dalaï-Lama។ សន្តិភាព គ្មាន យុត្តិធម៌ គ្មាន សេរីភាព គ្រាន់ តែជា ពាក្យ ទទេ សំរាប់ តែ បំពេ ឬ ធ្វើឲសង្ឃឹមខក តែប៉ុណ្ណោះ។ គេដឹងថា នៅចំពោះមុខ ជន ឬ របប ផ្តាច់ការ ខ្លះ វិធីសាស្ត្រ អហិង្សា វា គ្មាន អនុភាព អ្វី បន្តិច នោះឡើយ ព្រោះ ជន ឬ របប នោះវា គ្មាន គំនិត ដែល ស្របតាមវិចារណញ្ញាណ (rationnel) ដែល អាច រក ដំណោះស្រាយរួម ដើម្បី ប្រយោជន៍រួម ឬ ប្រយោជន៍ជាតិ បាន នោះទេ ហេតុនេះ ឯង ត្រូវ ចាំបាច់ ប្រើ មធ្យោបាយ ដែល មាន ច្បាប់រដ្ឋ ឬ ច្បាប់ ធម្មជាតិ គ្រប់គ្រង ទោះបី ជា អំពើ ហិង្សា ឬ អហិង្សា ដូច យ៉ាង បាតុកម្ម មហាជន ការបះបោរ ប្រជាជន សំរាប់ វាយ រំលំ របប ផ្តាច់ការ ឬ រំដោះជាតិ ពីរបប អាណានិគម ដែល មាន កើតឡើងជានិច្ច នៅក្នុង ប្រវត្តិសាស្ត្រ នៃ មនុស្សជាតិ។ ការបោះបង់ កម្លាំងណាមួយ ដែល ដែលអាចយកមកប្រើចាំបាច់ ព្រោះវា ស្របនឹងបរិបទ នៃ ស្ថានភាព សំរាប់ រំដោះ ប្រជាជាតិ គឺជា បាតប័ត្រ (résignation) តែប៉ុណ្ណោះ។

បច្ច័យភាព នៃ បរាជ័យ របប ផ្តាច់ការ មានពិត តែ ជួនកាល វា កើត មាន ឡើង នៅក្នុង ពេល វេលា មួយ តែ វា ហួសពេល រួច ទៅ ហើយ។ ទោះបី មាន ពាក្យ ស្លោក ថា -mieux vaut tard que jamais- (យឺតទៅចុះ ឲតែមាន) គឺ មិនមានន័យថា ត្រូវនាំគ្នាអោបដៃចាំ ឲវាកើតឡើង ដោយខ្លួនឯងនោះឡើយ ដូច ខ្មែរយើង នាំគ្នា ចាំ លើកចោលរហូត (calendes grecques) ព្រះបាទធម្មិក ចុះមកសង្គ្រោះជាតិខ្មែរ។ បច្ច័យភាព នៃ បរាជ័យ របបផ្តាច់ការ វាមាន នៅក្នុងធម្មជាតិ នៃ មនុស្សជាតិ ដែល មានមនុស្សលោក ជា នាដការ (acteur) សកម្ម មាន សីលធម៌ ស្គាល់សិទ្ធិរបស់ខ្លួន ជា មនុស្សលោក មិនមែន ជា នាដការ អកម្ម លះបង់សិទ្ធិអោយអ្នកណាម្នាក់ ដើម្បី ឲគេសំរេចលើ ជោគវាសនា របស់ ខ្លួន នោះឡើយ។ ការតស៊ូ របស់ មនុស្សលោក ដើម្បី សេចក្តីថ្លៃថ្នូរ របស់ខ្លួន ជាការតស៊ូ ធម្មានុរូប ឲ តែ ការតស៊ូនោះ ស្ថិត នៅ ក្នុង គោលការណ៍ នៃ សីលធម៌ និង នៃ ច្បាប់ សំរាប់ ការពារ សិទ្ធិ របស់ មនុស្សលោក។

ពលរដ្ឋ ម្នាក់ៗ ពុំអាច និយាយ ថា ខ្លួន ជា អ្នកស្នេហាជាតិ តែ រស់នៅ គ្មាន សកម្មភាព តាម កម្លាំង បញ្ញា ក្តី តាម កម្លាំង កាយ ក្តី ព្រោះ ពាក្យ ស្នេហាជាតិ នោះ វា គ្រាន់តែជា ការបំភ្លៃវោហារ (déclamation) តែប៉ុណ្ណោះ។ តែមនុស្ស ម្នាក់ៗ មាន សិទ្ធិ ជ្រើរើស ផ្លូវ នៃ ជវនចិត្តទៅរកសុភមង្គល កុំ អោយ តែ បំណងនោះ វា ជា បំណង បំរើ គំនិត អត្តានិយម អសីលធម៌ ព្រោះមនុស្ស ម្នាក់ៗ ជា សមាជិក នៃ មនុស្សជាតិ ដែល មាន សីលធម៌ ជា គ្រិះ។៚